


# កម្មវិធីទទួលបានភាសា និងការចូលរួមផ្នែកវប្បធម៌ (PLACE)

កម្មវិធីសម្រាប់ការទទួលបានភាសា និងការចូលរួមផ្នែកវប្បធម៌ (PLACE) របស់យើងត្រូវបានបង្កើតឡើងជាពិសេស ដោយមហាវិទ្យាល័យដើម្បីត្រៀមសិស្សដែលមានប្រវត្តិភាសានិយាយមិនមែនជាភាសាអង់គ្លេសអោយមានភាពរួចរាល់ក្នុងការផ្លាស់ប្តូរពីការរស់នៅនិងការរៀនសូត្រនៅក្នុងប្រទេសកំណើតរបស់ពួកគេចូលទៅក្នុងថ្នាក់រៀនចំបងនៅមហាវិទ្យាល័យ St Leonard និងជីវិត នៅប្រទេសអូស្ត្រាលី។

កម្មវិធីមានកត្តាចំនួន៤ពាក់ព័ន្ធគ្នា៖

## ការណែនាំសិស្ស

ដំនើរការនៃការណែនាំសិស្សអន្តរជាតិចាប់ផ្តើមបន្ទាប់ពីទទួលបានលិខិតផ្តល់ជូន។ ទំនាក់ទំនងនឹងត្រូវបានបង្កើតឡើងរវាងសិស្ស និងបុគ្គលិកបង្រៀន និងបុគ្គលិកថែទាំសុខុមាលភាពកាយនិងចិត្ត, ផ្ទះស្នាក់នៅឪពុកម្តាយដែលមានសក្តានុពលរបស់ពួកគេ, និងមិត្តរួមថ្នាក់នាពេលអនាគត។ ភាពញឹកញាប់នៃការទំនាក់ទំនងនឹងកើនឡើងនៅពេលកាលបរិច្ឆេទចាប់ផ្តើមកម្មវិធីខិតជិតមកដល់ ដើម្បីសម្រួលដល់ការផ្លាស់ប្តូរជីវិតទៅនៅឯមហាវិទ្យាល័យដោយរលូន និងចូលទៅរស់នៅនិងរៀននៅប្រទេសអូស្ត្រាលី។

## ផ្ទះស្នាក់តាមសហគមន៍

ពេលមកដល់ប្រទេសអូស្ត្រាលី, សិស្សអន្តរជាតិដែលមិនរស់នៅជាមួយសមាជិកគ្រួសារ ឬអាណាព្យាបាលដែលបានទទួលសិទ្ធិ នឹងត្រូវបានផ្គូរផ្គងជាមួយគ្រួសារផ្ទះស្នាក់មួយដោយមហាវិទ្យាល័យ។បណ្តាញស្នាក់នៅតាមផ្ទះរបស់យើង រួមមានអតីតនិស្សិត, សមាជិកបុគ្គលិក, ឪពុកម្តាយអតីតសិស្សនិងក្រុមគ្រួសាររបស់សិស្សបច្ចុប្បន្ន។សំរាប់ព័ត៌មានលម្អិតបន្ថែមសូមអានខិតប័ណ្ណផ្ទះស្នាក់អន្តរជាតិរបស់យើង។

## ថ្នាក់ភាសាអង់គ្លេសល្អិតល្អន់

ដំបូង, សិស្សអន្តរជាតិនឹងចូលរួមក្នុងថ្នាក់ភាសាអង់គ្លេសល្អិតល្អន់ដែលបានគ្រោងជាផ្នែកមួយរបស់PLACE, ស្ថិតក្នុងកាលវិភាគមហាវិទ្យាល័យធម្មតា។ ថ្នាក់ទាំងនេះមានលក្ខណៈផ្ទាល់ខ្លួន ហើយផ្តោតលើការអភិវឌ្ឍការអាន, ការស្តាប់, ការនិយាយ និងវាក្យសព្ទរបស់សិស្សម្នាក់ៗ។ ក្នុងអំឡុងពេលកម្មវិធីរបស់ពួកគេ, យើងនឹងជួយសិស្សក្នុងការជ្រើសរើសមុខវិជ្ជា ហើយនៅពេលបញ្ចប់ ពួកគេនឹងបន្តសិក្សាភាសាអង់គ្លេសជាភាសាបន្ថែម (EAL) ។ សិស្សអន្តរជាតិនឹងចូលរួមសន្និបាត, ធ្វើជាសមាជិកម្នាក់របស់ក្រុមអ្នកណែនាំ និងចូលរួមក្នុងកម្មវិធីក្រៅថ្នាក់រៀនជាច្រើនរបស់មហាវិទ្យាល័យ។

## បន្តគាំទ្រដល់ការសិក្សា

សិស្សអន្តរជាតិនឹងនៅតែស្ថិតនៅក្នុង PLACE រហូតដល់ពួកគេបានឈានដល់កម្រិតសមត្ថភាពភាសាអង់គ្លេសដែលអនុញ្ញាតឱ្យពួកគេចូលក្នុងថ្នាក់ធម្មតាបាន។

ការផ្លាស់ប្តូរនេះនឹងចាប់ផ្តើមជាមួយមុខវិជ្ជាមួយរឺច្រើន ហើយកើនឡើងជាលំដាប់រហូតដល់ពួកគេត្រូវបានបញ្ចូលទៅក្នុងថ្នាក់ធម្មតា។ សិស្សអន្តរជាតិក៏នឹងបន្តទទួលបានការគាំទ្រពីគ្រូរបស់ពួកគេរហូតដល់បញ្ចប់ការសិក្សា, បន្ទាប់ពីនោះពួកគេក្លាយជាOld Collegianដោយស្វ័យប្រវត្តិ-ដែលជាកម្មវិធីអតីតនិស្សិតមហាវិទ្យាល័យ។

សិស្សអន្តរជាតិដែលចុះឈ្មោះនៅមហាវិទ្យាល័យមិនតម្រូវឱ្យបង់ថ្លៃបន្ថែមសម្រាប់ PLACE ទេ។

សំរាប់ព័ត៌មានបន្ថែមសូមអានឯកសារ ថ្លៃឈ្នួល និងថ្លៃសេវាសំរាប់សិស្សអន្តរជាតិរបស់យើង។